**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:១៣៩
ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១
**សាលដីកា**
លេខ:៧
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............. ជាប្រធាន
២-លោក ........... ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ................. ជាចៅក្រម
៥-លោក ............ ជាចៅក្រម
៦-លោក ............. ជាចៅក្រម
៧-លោក ............ ជាចៅក្រម
៨-លោក ............. ជាចៅក្រម
៩-លោក ............. ជាចៅក្រម

**ក្រឡាបញ្ជី**

-កញ្ញា ................

**តំណាងមហាអយ្យការ**

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ០៩(ឈ)ចុះថ្ងៃទី៣០-០១-២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទអ្នកស្រីអេ អាយុ៤៨ ជាតិខ្មែរ របរលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥៦អឺសូន្យ ផ្លូវ១២៦ ក្រុម១៧ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

**មេធាវី គ្មាន** ។

- និងចុងចម្លើយឈ្មោះលោកសគសអាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ វេជ្ជបណ្ឌិត ទីលំនៅសព្វថ្ងៃផ្ទះលេខ១៣៦ ផ្លូវលេខ១៣ សង្កាត់ផ្សារ កណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ **មេធាវី គ្មាន** ។

**<u>កម្មវត្ថុបណ្តឹង:</u>ប្តឹងសុំលែងលះ** ។

បានឃើញបណ្ដឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះសគសនិង បណ្ដឹងសាទុក្ខលេខ៧០ ចុះថ្ងៃទី១២-០៣-២០០១ របស់អ្នកស្រីនាងវអេ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៣៩ ចុះថ្ងៃទី១៨.៥.២០០១ របស់ តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១៨-១១-៩៨ របស់ដើមចោទឈ្មោះអ្នកស្រីវអេ ប្ដឹងសុំលែងលះប្ដីឈ្មោះសគសដោយសំអាងហេតុថាតាំងពីរៀបការជាប្ដីប្រពន្ធមកខ្លួនប្ដីខ្លួន មិនជួយរកស៊ីចិញ្ចឹមកូនគិតតែលេងល្បែងស៊ីសងរករឿងវាយដំខ្លួននិងកូនៗ គ្មានលោះថ្ងៃណាឡើយ។ នៅថ្ងៃទី៣០.៦.៩៧ ប្ដីខ្លួនបានចាកចេញពីផ្ទះ ព្រមទាំងវាយដំខ្លួន និងកូនទាំងបួនហើយបានពុះទូរ ប្រមូលយកមាសប្រាក់ ប្លង់ផ្ទះទាំងពីរល្វែងប្លង់ដីយកទៅបញ្ចាំគេ ដើម្បីចូលកាស៊ីណូ ហូលីដេ ។ ក្រោយមកខ្លួនបានខ្ចីលុយគេ យកទៅលួសយកប្លង់ផ្ទះ និងប្លង់ដីមកវិញ ។

បានឃើញដីកាសម្រេច របស់តុលាការក្រុងភ្នំពេញលេខ៤២(ក) ចុះថ្ងៃទី១៩-១១-៩៨ ដែលមានខ្លឹមសារដូចតទៅ ៖

១. ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១៨-១១-៩៨ របស់ដើមចោទឈ្មោះនាង វអេ ប្ដឹងសុំហាមឃាត់មិនឱ្យឈ្មោះសគសលក់ដូរ ផ្ទេរសិទ្ធិ បញ្ចាំឬធ្វើអំណោយទៅ អ្នកដទៃនូវដីឡូត៍លេខ១៨៤ ផ្លូវ៦៣ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ផ្ទះលេខ១៣៦ ផ្លូវ១៣ សង្កាត់ផ្សារកណ្ដាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ និងផ្ទះលេខ៥៦អឺសូន្យផ្លូវ១២៦ក្រុម១៧ សង្កាត់ផ្សារថ្មី ទណ្ឌដូនពេញ ក្រុងភ្នំពេញ ជាបណ្ដោះអាសន្ន នោះទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ហាមឃាត់មិនឱ្យឈ្មោះសគសលក់ដូរ ផ្ទេរសិទ្ធិ បញ្ចាំឬធ្វើ អំណោយទៅអ្នកដទៃ នូវដីឡូត៍លេខ១៨៤ ផ្លូវ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុង ភ្នំពេញ ផ្ទះលេខ១៣៦ ផ្លូវ១៣សង្កាត់ផ្សារកណ្ដាល១ ទណ្ឌដូនពេញ ក្រុងភ្នំពេញ និងផ្ទះលេខ៥៦អឺសូន្យ ផ្លូវ១២៦ ក្រុម១៧ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ជាបណ្ដោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់រឿងអង្គសេចក្ដីចប់ជាស្ថាពរ ។

៣. បង្គាប់ឱ្យឈ្មោះនាងវអេ បង់ប្រាក់ប្រដាប់ក្ដី២.០០០រៀល ។

៤. បើគូភាគីមិនសុខចិត្តនិងដីកានេះ មានសិទ្ធិប្ដឹងទាស់ក្នុងរយៈពេល១៥ថ្ងៃគិតពីថ្ងៃបានទទួលដំណឹងពីដីកានេះតទៅ ។

តុលាការក្រុងភ្នំពេញបានចេញដីកាសម្រេចកិច្ចការប្រញាប់លេខ០២(៨) ចុះថ្ងៃទី១១-០១-៩៩ ដែលមានខ្លឹមសារ ដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងហាមឃាត់ចុះថ្ងៃទី០៤-០១-៩៩ របស់ដើមចោទឈ្មោះសគសទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ហាមឃាត់ឈ្មោះនាងវួច អេង មិនឱ្យជួលលក់ដូរបញ្ចាំផ្ទេរកម្មសិទ្ធិ ឬធ្វើអំណាចដល់អ្នកដទៃនូវតូបលេខ៩៣ស្ថិតក្នុងផ្សារធំថ្មី ប្រាក់តម្កល់ក្នុងធនាគារឥណទានកម្ពុជាចំនួន៥០.០០០ដុល្លារ ក្នុងវិញ្ញាបនប័ត្រចុះថ្ងៃទី០៨-០៧-៩៤ និងប្រាក់ចំនួន១០០.០០០ដុល្លារ ក្នុងវិញ្ញាបនប័ត្រចុះថ្ងៃទី១២ ១២.៩៤ និងប្រាក់ចំនួន១៥០.០០០ដុល្លារ ដែលកំពុងគ្រប់គ្រងដោយនាងវអេ ទុកជាបណ្ដោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្ដី ។

៣. បង្គាប់ឱ្យដើមចោទឈ្មោះសគសបង់ប្រាក់ប្រដាប់ក្ដីចំនួន២.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទ បានបង់ទុករួចជាស្រេច

៤. ដីកាសម្រេចនេះ មានអនុភាពយកទៅអនុវត្តភ្លាមៗទេនោះជាមានបណ្ដឹង ឧទ្ធរណ៍ក៏ដោយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៤៩(ក)ចុះថ្ងៃទី១៦-០៦-៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១៨-១១-៩៨ របស់ដើមចោទឈ្មោះនាងវួច-អេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២. ឱ្យឈ្មោះនាងវអេ និងឈ្មោះសគសដាច់សមគ្គសង្វាស តាមការព្រមព្រៀងគ្នា ចាប់ពីថ្ងៃនេះតទៅ ។

៣. ឱ្យឈ្មោះនាងវអេ ស្ថិតនៅជាភាពមេម៉ាយចំនួន៣០០ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤. ប្រគល់កូនឈ្មោះសេង សុធី ភេទប្រុសអាយុ១៨ឆ្នាំ សេង សុធារ៉ា ភេទប្រុសអាយុ១៦ឆ្នាំ សេង សុគន្ធរិទ្ធិ ភេទប្រុស អាយុ១៤ឆ្នាំ និង ឈ្មោះ សេង សុគន្ធារី ភេទស្រី អាយុ១២ឆ្នាំ ឱ្យទៅឈ្មោះនាងវអេ គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាចាប់ ពីថ្ងៃនេះតទៅ និងបង្គាប់ឱ្យឈ្មោះសគសបង់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព រហូតដល់កូន នីតិភាព ឱ្យទៅឈ្មោះនាងវអេ ។

៥-បែងចែកទ្រព្យសម្បត្តិរួមមានដីឡូត៍លេខ១៨៤ ផ្លូវលេខ៦៣ សង្កាត់ បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ផ្ទះលេខ១៣៦អឺសូន្យ អ៊ី១ អ៊ី២ ផ្លូវលេខ១៣ សង្កាត់ផ្សារកណ្ដាល១ ទណ្ឌដូនពេញ ក្រុងភ្នំពេញ ផ្ទះលេខ៥៦អឺសូន្យ ផ្លូវ១២៦ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ និងតូបលក់មាសលេខ៩៣ នៅផ្សារធំថ្មីឱ្យទៅឈ្មោះវអេ ចំនួន៣/៤ និង ឱ្យឈ្មោះសេង គឹមស៊ុយ១/៤តាមតម្លៃជាក់ស្ដែង តែទ្រព្យសម្បត្តិទាំងនោះ ត្រូវដកសងឱ្យទៅឈ្មោះឌី ចាន់ធី ចំនួន១៦.០០០ដុល្លារ ដែលឈ្មោះនាងវអេ បានខ្ចីកាលពីថ្ងៃ០៩.១២.៩៧ ។

៦. រំលាយចំណងអាពាហ៍ពិពាហ៍របស់ឈ្មោះនាងវអេ និងឈ្មោះសគសចាប់ពីថ្ងៃនេះតទៅ ។

៧. បង្គាប់ឱ្យឈ្មោះសគសបង់ប្រាក់ប្រដាប់ក្ដី៧.០០០រៀល គឺពន្ធ ចុះបញ្ជី និងពន្ធហ្នឹង១.៨០០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់សាក្សី២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ

៣.០០០រៀលប្រាក់នេះ បានកាត់យក ពីប្រាក់៧.០០០រៀល ដែលដើមចោទ បានបង់ទុកជាស្រេច ។ កាលបើហួសកំណត់ឧទ្ធរណ៍ហើយ បង្គាប់ឱ្យឈ្មោះសគសសងប្រាក់៧០០០រៀល ទៅដើមចោទវិញ ។

៨. សាលក្រមនេះជំនុជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូភាគីសម្រេច បើកផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លខ៣៩(ក) ចុះថ្ងៃទី២៤-៦-៩៩ របស់លោកសគសនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧២៨ ចុះថ្ងៃទី៣០-០៩-៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃ២៤-០៦-៩៩ របស់ឈ្មោះសគស។

២-មិនទទួលពាក្យបណ្តឹង ចុះថ្ងៃទី១០-០៨-៩៩ របស់ឈ្មោះឆគឆនិងពាក្យចុះថ្ងៃទី១៥-០៨-៩៩ របស់ឈ្មោះសេង លឹមខេង ដោយផ្ទុយពីទម្រង់ និងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៩៤(ក) ចុះថ្ងៃទី១៦-០៦-៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ប៉ុន្តែលើកលែងចំណុចទី៤ និងទី៥ ត្រូវកែប្រែជាថ្មី ។

៤-(ក)ប្រគល់កូនឈ្មោះសេង សុធារ៉ា ភេទប្រុស អាយុ១៦ឆ្នាំ សេង សុគន្ធារិទ្ធិ ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះសេង សុគន្ធារី ភេទស្រី អាយុ១២ឆ្នាំ តាម សំណូមពរ របស់កូនទាំងបីនាក់ ទៅឱ្យឈ្មោះនាងវអេ គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សារហូតដល់ កូនទាំងបីនាក់នេះក្លាយជានីតិជន ។

(ខ) បង្គាប់ឱ្យឈ្មោះសគសបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងបី នាក់នេះ តាមរបបរដ្ឋកំណត់ រហូតដល់ កូនក្លាយជានីតិជនទៅឱ្យឈ្មោះនាងវអេ ។

៥. បែងចែកប្រាក់ដែលតម្កល់ទុកនៅធនាគារឥណទាន កម្ពុជាជាពីរចំណែកស្មើៗគ្នា រវាងប្តីនិងប្រពន្ធ បើសិនជាមានបន្សល់ទុកក្នុងធនាគារ

៦(ក) ប្រគល់ផ្ទះលេខ១៣៦អឺសូន្យ អ៊ី១ អ៊ី២ ផ្លូវលេខ១៣ សង្កាត់ផ្សារ កណ្តាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទាំងមូលទៅឱ្យលោកសគសកាន់កាប់និងគ្រប់គ្រង ជាកម្មសិទ្ធិ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

ខ- ប្រគល់ផ្ទះលេខ៥៦អឺសូន្យ ផ្លូវលេខ១២៦ សង្កាត់ផ្សារថ្មីទី២ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ទៅឱ្យឈ្មោះនាងវអេ កាន់កាប់ និងគ្រប់គ្រងជាកម្មសិទ្ធិនៅពេលដែល សាលដីកានេះចូលជាស្ថាពរ ។

គ- បែងចែកតូបលក់មាសលេខ៩៣ ស្ថិតនៅផ្សារធំថ្មី និងដីឡូត៍លេខ១៨៤ផ្លូវលេខ៦៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ជាតម្លៃជាពីរចេណកស្មើៗគ្នា

៧- ទុកសិទ្ធិឱ្យឈ្មោះសគខនិងឈ្មោះឆគឆប្តឹងទាមទារ ប្រាក់ពីរឈ្មោះសគសនិងឈ្មោះនាងវអេ ទៅតុលាការថ្នាក់ក្រោម តាមផ្លូវច្បាប់ ។

៨- សម្រេចកាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលគឺ ពន្ធចុះបញ្ជី និង ពន្ធហ្មឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរ តុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

៩. សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤២៦ ចុះថ្ងៃទី០១-១០-៩៩ របស់អ្នកស្រីវអេ មិនសុខចិត្តនឹងសេច ក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២៥ ចុះថ្ងៃទី២៩-០៦-២០០០ របស់តុលាការកំពូល ដែលមានខ្លឹមសារដូចតទៅ ៖

១- ទទួលបណ្តឹងសាទុក្ខលេខ៤២៦ ចុះថ្ងៃទី០១-១០-៩៩ របស់អ្នកស្រីនាងវអេ ទុកជាត្រឹមត្រូវ តាមទម្រង់ នឹងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧២៨ ចុះថ្ងៃទី៣០-០៩-៩៩ របស់ សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៨៩ ចុះថ្ងៃទី០៦-១២-៩៩ របស់តុលាការកំពូល ទៅ សាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៥.០០០រៀល ដែលអ្នកស្រីនាងវអេបានបង់រួចហើយគឺពន្ធចុះ បញ្ជីក្តី និងពន្ធហ្មឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យលោកសគសសងប្រាក់ចំនួន១៩.០០០រៀល នេះទៅអ្នកស្រីនាងវអេ ។

៥. សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៩-០៦-២០០០។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩១(ឈ)ចុះថ្ងៃទី៣០-០១-២០០១ របស់សាលា ឧទ្ធរណ៍ សម្រេចលើកទី២ ដែលមានខ្លឹមសារដូចតទៅ ៖

១. ទទួលជំនុំជំរះរឿងរដ្ឋប្បវេណីលេខ៧២ ចុះថ្ងៃទី១៩.០៩.២០០០ របស់សាលា ឧទ្ធរណ៍ឡើង វិញ តាមអំណាចសាលដីកាលេខ១២៥ ចុះថ្ងៃទី២៩-០៦-២០០០ របស់តុលាការកំពូល ។

២. ឱ្យឈ្មោះវអេ និងសគសដាច់សមគ្គសង្វាសពីគ្នាចាប់ពី ថ្ងៃនេះតទៅ តាមការព្រមព្រៀង ។ (មាត្រា៤០នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ) ។

៣. ប្រគល់កូន០៣នាក់ឱ្យទៅនាងវអេ គ្រប់គ្រងចិញ្ចឹមថែរក្សាបីបាច់ រហូតដល់កូនទាំង០៣នាក់ ក្លាយជានីតិជនមាន ៖ ឈ្មោះសេង សុធារ៉ា ភេទប្រុស អាយុ១៦ឆ្នាំ ឈ្មោះសេង សុគន្ធរិទ្ធ ភេទប្រុស អាយុ១៤ឆ្នាំ ឈ្មោះសេង សុគន្ធរី ភេទស្រី អាយុ១៣ឆ្នាំ ។

៤. ប្រគល់ផ្ទះលេខ៥៦វើសូន្យ ផ្លូវ១២៦ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ឱ្យទៅនាងវអ កាន់កាប់ និងគ្រប់គ្រងជាកម្មសិទ្ធិ និងផ្ទះលេខ១៣៦ទីសួន្យ.អ៊ុ.អ៊ី២ ផ្លូវលេខ១៣ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ឱ្យទៅឈ្មោះសគសកាន់កាប់គ្រប់គ្រង ជាកម្មសិទ្ធិតទៅតាមការព្រមព្រៀងរបស់គូ ភាគី

៥. ប្រគល់តូបលេខ៩៣ស្ថិតនៅផ្សារធំថ្មីឱ្យទៅឈ្មោះសគសកាន់ កាប់តទៅ ។

៦- ប្រគល់ដីឡូតិ៍លេខ១៨៤ ផ្លូវលេខ៦៣ សង្កាត់បឹងកេងកងទី១ ខណ្ឌ ចំការមន ក្រុងភ្នំពេញ ឱ្យឈ្មោះវអ កាន់កាប់គ្រប់គ្រងដើម្បីជាប្រយោជន៍កូនៗ ទាំង៣នាក់ ដោយពុំចាំបាច់ឱ្យឈ្មោះសគសបង់ ប្រាក់អាហារកិច្ចឡើយ ។

៧- រឹបអូសប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះ បញ្ជីក្តី និងពន្ធហ្នឹង ចំនួន២.៥៥០រៀល វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល ចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

៨. សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវ ប្តឹងសាទុក្ខតាម កំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៥៤ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះ សគស និងបណ្តឹងសាទុក្ខលេខ៧០ ចុះថ្ងៃទី១២.៣.២០០១ របស់អ្នកស្រីនាងវអ ។

បានឃើញសារណាការពាររបស់ឈ្មោះនាងវអ ចុះថ្ងៃទី២៤-មេសា-២០០០។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះសគសចុះថ្ងៃទី០២ មករា-២០០០។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាយ្យការថា ៖

សាលដីការដ្ឋប្បវេណីលេខ០៩(ឈ)ចុះថ្ងៃទី៣០.០១-២០០១ របស់សាលាឧទ្ធរណ៍ដែលបាន សម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

**សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។**

បានស្តាប់ចម្លើយរបស់ឈ្មោះសគសថា ៖ បានជាខ្ញុំបាទប្តឹង ព្រោះខ្ញុំមិនសុខចិត្តនិងសេចក្តី សម្រេចរបស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣ទី៦ប្រាក់១៥ម៉ឺនដុល្លាអាមេរិក ផ្ញើនៅធនាគារ និងប្រាក់ខ្ចីគេ ៣៥.០០០ដុល្លារ និងមិនសុខចិត្តរឿងដីខ្ញុំបាទសូមជម្រាបថា៖ ប្រាក់១៥ម៉ឺនដុល្លារនេះគឺតម្កល់នៅ ធនាគារ មិនទាន់បានដកទេ ហើយម្ចាស់ធនាគារត្រូវជាក្មួយបង្កើតរបស់នាងវអ ហើយបានផ្សំគំនិតគ្នាធ្វើ លិខិតផ្សេងដកលុយ ឯវិក័យប័ត្រដើម គឺនៅខ្ញុំបាទកាន់កាប់។ ខ្ញុំបាទបានទៅទារយកប្រាក់នេះ តែនាងវអ ជាមិនឱ្យទៅទារ ព្រោះយល់ដល់ក្មួយគេ ខ្ញុំបាទមិនត្រឹមតែទារពីម្ចាស់ធនាគារទេ ម្តាយម្ចាស់ធនគោរទៀត

ថាឱ្យរកលុយឱ្យខ្ញុំបាទវិញ ។ ចំពោះរឿងដីឡូត៍ គឺជាដីអំណោយពីឈ្មោះសេង វិន បានឱ្យមកខ្ញុំបាទផ្ទាល់ ខ្ញុំបាទសូមទាមទារយកតែម្នាក់ឯង និងសូមឱ្យចែកប្រាក់ដែលដាក់នៅធនាគារនោះ ។

បានស្តាប់ចម្លើយរបស់អ្នកស្រីវអេ ថា ៖ បានជានាងខ្ញុំប្តឹង ព្រោះឈ្មោះ សគសមិនដែលបានចិញ្ចឹមកូនទេ គិតតែពីដើរលេងខ្ចីលុយគេទៅហ្វូលីដេ ទើបនាងខ្ញុំយកចិញ្ចឹមកូនទេ កូនទុកឱ្យនាងខ្ញុំចិញ្ចឹមទាំងអស់ ។ នាងខ្ញុំសូមប្រគល់ផ្ទះនៅផ្សារកណ្តាលនោះឱ្យទៅគាត់ ដើម្បីឱ្យវាចប់រឿងរ៉ាវ ក្រៅពីនោះនាងខ្ញុំសូមយកទាំងអស់ ព្រោះនាងខ្ញុំជាអ្នកចិញ្ចឹមកូន៤នាក់ ។ចំពោះដីនេះគឺជាដីរួមដែលនាងខ្ញុំបានទៅទិញជាមួយគាត់គឺគ្មានអ្នកណាឱ្យនោះទេ គឺទិញ៩តំលឹងមាស ហើយតូបនៅផ្សារថ្មីក៏នាងខ្ញុំជាអ្នកទិញដែរ ព្រោះខ្ញុំជាអ្នករកស៊ី ។ ចំពោះលុយ១៥ម៉ឺនដុល្លានោះនាងខ្ញុំទទួល ស្គាល់ ព្រោះនាងខ្ញុំជាអ្នកយកទៅដាក់ធនាគារ ដើម្បីសុំសារទៅលេងអាមេរិកពេលបានវិសារទៅរយៈពេល៦ខែ ឯណោះតែនាងខ្ញុំមិនបាននៅទេ គឺនៅតែជាង១ខែនាងខ្ញុំត្រឡប់មកវិញ ហើយលុយនោះបានដកយកមករកស៊ីរួមគ្នាអស់ហើយ ។ ចំពោះប្រាក់គាត់ខ្ចី៣៥០០០ដុល្លារ នាងខ្ញុំពុំបានដឹងធទេ ព្រោះគាត់ពូកែធ្វើលិខិតក្លែងក្លាយណាស់ ។ នាងខ្ញុំយល់ព្រមតាមការសម្រេចរបស់សាលាឧទ្ធរណ៍ទាំងអស់តែ សូមទុកតូបនៅផ្សារថ្មី ដើម្បីលក់សងបំណុលដែលគាត់បានខ្ចីគេ ។

បានស្តាប់ចម្លើយរបស់លោកសគសថា៖ ខ្ញុំបាទមិនបានក្លែងហត្ថលេខាអ្វីដូច នាងវអេ និយាយនោះទេ ហើយខ្ញុំបាទក៏មិនបានទៅពុះទ្វារអ្វីដែរ ខ្ញុំបាទសុំឱ្យនាងវអេ ស្បត់ នៅចំពោះមុខតុលាការ អំពីរឿងលុយនៅធនាគារ បើនាងហ៊ានស្បត់នោះខ្ញុំមិនយកសូម្បីតែមួយរៀលទេ ហើយចំពោះរឿងដីបើនាងថា ដីនោះជាដីទិញ តើមានលិខិតស្នាមអ្វីមកបញ្ជាក់ ។

មេធាវី (សេង សៀ) រឿងនេះ ស្ថិតនៅក្នុងរង្វង់គ្រួសារ ហើយរឿងរ៉ាវកូនក្តីខ្ញុំបាទ បានបញ្ជាក់រួចហើយ តែខ្ញុំបាទសូមបញ្ជាក់បន្ថែមថា ៖ ចំពោះលុយ១៥ម៉ឺនដុល្លារនេះគឺមិនទាន់បានដក ពីធនាគារទេ ដោយផ្អែកតាមលិខិតស្នាមដែលមាននៅលើដៃកូនក្តីខ្ញុំបាទ ។ ហើយឈ្មោះស៊ី វួចជន ជាម្ចាស់ធនាគារត្រូវក្មួយរបស់នាងវអេ ។

- ចំពោះប្រាក់ជំពាក់គេ៣៥.០០០ដុល្លារ គឺក្នុងការរកស៊ីរួមគ្នាក្នុងរង្វង់គ្រួសារ សូមបែងចែក ឱ្យនាងទទួលខុសត្រូវ ។

- ចំពោះកូន កូនក្តីខ្ញុំបាទ សូមទទួលខុសត្រូវទាំងអស់នៅចំពោះមុខច្បាប់ ។

- ចំពោះដីគឺជាអំណោយទាន ពីឈ្មោះសេង វិន ឱ្យមកឈ្មោះសគសដោយមានលិខិតស្នាមត្រឹមត្រូវ ។

សូមក្រុមប្រឹក្សាមេត្តារកយុត្តិធម៌ ឱ្យកូនក្តីខ្ញុំបាទផង ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០១ របស់លោក សគសនិង បណ្តឹងសាទុក្ខលេខ៧០ ចុះថ្ងៃទី១២.៣.២០០១ របស់អ្នកស្រីវអេ ស្ថិតនៅ ក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា សារណាចុះថ្ងៃទី០១.០៦.០១ និងចុះថ្ងៃទី២៧.៧-២០០១ របស់ចុងចម្លើយ ដែលលើកឡើងថា ដើមចោទ បានឃុបឃិតជាមួយឈ្មោះឌី ចាន់ នី ធ្វើលិខិតក្លែងបន្លំថ្ងៃ ខែ ឆ្នាំ បំភាន់តុលាការយកតូបលេខ៩៣ ស្ថិតនៅផ្សារធំថ្មីដាក់បញ្ចាំឱ្យឈ្មោះឌី ចាន់នី ក្នុងតម្លៃ ១៦.០០០អាមេរិក យកប្រាក់តែម្នាក់ឯង ។ ប៉ុន្តែតាមការពិតដើមចោទថ្នូលឱ្យឈ្មោះឌី ចាន់នី រយៈពេល៣៦ខែ ក្នុង១ខែ ៥០០ដុល្លាអាមេរិក ដែលថាតូបនេះខ្លួនបានប្តឹងតុលាការក្រុងភ្នំពេញហាមឃាត់ កុំឱ្យលក់ដូរបញ្ចាំដូលឬផ្ទេរសិទ្ធិឱ្យអ្នកដទៃរួចហើយ និងថាដើមចោទបំពានលើច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារត្រង់មាត្រា៣៦ និង៣៧ ដែលស្តីពីការគ្រប់គ្រងចាយវាយឬធ្វើអំណោយឱ្យអ្នកដទៃដែលត្រូវតែមានការព្រមព្រៀងពីសហព័ន្ធទាំង២នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះករណីនេះ ។

- ដីកាសម្រេចកិច្ចការប្រញាប់លេខ០២(ជ) ចុះថ្ងៃទី១១- ០១- ៩៩ ធ្វើក្រោយលិខិតដាក់បញ្ចាំចុះថ្ងៃទី០៩-១២.៩៧ របស់ដើមចោទ ។

-យល់ឃើញថាលិខិតចុះថ្ងៃទី២៨.០១.៩៧ និងលិខិតចុះថ្ងៃទី១០.០២.៩៧របស់ចុងចម្លើយ ដែលខ្ចីប្រាក់ពីអ្នកស្រីសេង លឹមខេង និងពីលោកឆៃ គឹមធន និងលិខិតកិច្ចសន្យាបញ្ចាំតូប ចុះថ្ងៃទី៩-១២-៥៧ របស់អ្នកស្រីវអេ ឱ្យទៅឈ្មោះ ឌី ចាន់នី ធ្វើឡើងដោយពុំមានការយល់ព្រមពីសហព័ន្ធម្ខាងទៀតដូចគ្នា តុលាការកំពូលពុំគប្បីលើកមកពិចារណាឡើយ ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ចុងចម្លើយមុននឹងចុះចោលប្រពន្ធ និងកូនទៅរស់នៅផ្សេងនោះ បានវាយដំធ្វើបាបប្រពន្ធកូន និងបានពុះទ្វាយកប្រាក់ និងគ្រឿងអលង្ការទៅជាមួយខ្លួនអស់មួយចំនួនដូចមានចម្លើយសាក្សីឈ្មោះកែវ ទ្រី និងឈ្មោះឃិន គឹមសេង ដែលជាអ្នកបំរើនៅផ្ទះជាមួយ និងជាក្មួយចុងចម្លើយជាភស្តុតាងស្រាប់ ។

- យល់ឃើញថា ចម្លើយសាក្សីឈ្មោះញាណ សេង ហុង ជានាយសន្តិសុខធនាគារ ឥណទានបានឆ្លើយអះអាងថា ដើមចោទបានបើកយកប្រាក់ចេញពីធនាគារតាំងពីថ្ងៃទី០១-០៣-៩៥ ប្រាកដមែន ។ ដូច្នេះប្រាក់នេះប្តីប្រពន្ធបានបើកយកមកចាយវាយ និងប្រើប្រាស់តាំងពីនៅក្នុងចំណងអាពាហ៍ពិពាហ៍នៅឡើយពិតប្រាកដមែន ។

- យល់ឃើញថាដីឡូតិ៍លេខ១៨៤ ដែលចុងចម្លើយអះអាងថាជាទ្រព្យអច្ច័យទារទទួលពី ឈ្មោះ សេង រិន និងនាងរូ ធីលូវ ពីឆ្នាំ១៩៨៩ មកជាការពុំត្រឹមត្រូវទេ ពីព្រោះដីនេះបានមកក្នុងរយៈពេលចំណង អាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធនៅឡើយ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថាជាទ្រព្យអច្ច័យទានដូចការ អះអាងរបស់ចុងចម្លើយឡើយ ។

- យល់ឃើញថាការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិ ច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខតួក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី០១-០៣-២០០១ របស់លោកសគសនិងបណ្តឹងសា ទុក្ខលេខ៧០ ចុះថ្ងៃទី១២.០៣.២០០១ របស់អ្នកស្រីវអេ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធ ចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ០៩(ឈ) ចុះថ្ងៃទី៣០-០១-២០០១ របស់សាលា ឧទ្ធរណ៍ ទុកជាបានកាំរពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រីវអេ បានបង់ខ្លួនឯង និងបង់ជួសលោក សគសនៅតុលាការ កំពូលរួមត្រូវ ៣៨.០០០រៀល គឺ ៖

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយ តម្រូវឱ្យ លោកសគសសងប្រាក់១៩.០០០រៀល នេះទៅអ្នកស្រីវអេ វិញ ។ ប្រាក់សល់ចំនួន១៩.០០០រៀល ប្រគល់ឱ្យអ្នកស្រីវអេ វិញ ។

៤. សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២។